**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៣៣...សជណន

# សារលិខិត

## សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## អបអរសាទរទិវាជាតិ និងអន្តរជាតិប្រឆាំងអំពើពុករលួយ ៩ ធ្នូ

**- សូមក្រាបបង្គំសម្តេចព្រះមហាសង្ឃរាជទាំងពីរ គណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ!**
**- សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី!**
**- បងប្អូនជនរួមជាតិទាំងអស់ ជាទីស្រឡាញ់!**

ថ្ងៃទី៩ ធ្នូ ជារៀងរាល់ឆ្នាំ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ (អ.ស.ប) កំណត់ជាទិវាប្រឆាំងអំពើពុករលួយ ។ ស្ថាប័ន អ.ស.ប ទទួលបន្ទុកប្រយុទ្ធប្រឆាំងអំពើពុករលួយមានឈ្មោះថា អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងអំពើពុករលួយ ហៅកាត់ថា អ៊ុនកាក់ UNCAC (The United Nations Convention Against Corruption) ដែលបានបង្កើតឡើងនា មហាសន្និបាត អ.ស.ប នៅថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០០៣ និងចូលជាធរមាននៅថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០០៥ ។ មកដល់ខែតុលា ឆ្នាំ ២០២៣ នេះ ស្ថាប័នប្រឆាំងអំពើពុករលួយ អ.ស.ប អ៊ុនកាក់ មានរដ្ឋជាសមាជិកចំនួន ១៩០ ប្រទេស លើ ១៩៣ ប្រទេស ។ ព្រះរាជាណាចក្រកម្ពុជា បានចូលជាសមាជិកនៅថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០៧ មកម្ល៉េះ ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ក្នុងនាមជារដ្ឋភាគី នៃអនុសញ្ញា អ.ស.ប ស្តីពីការប្រឆាំងអំពើពុករលួយ ទូលព្រះបង្គំខ្ញុំ ខ្ញុំព្រះករុណាខ្ញុំ សូមសម្តែងនូវក្តីសោមនស្សរីករាយ អបអរសាទរ ចំពោះទិវាប្រឆាំងអំពើពុករលួយ ៩ ធ្នូ ដែលជាទិវាអន្តរជាតិ និងជាទិវាមួយរបស់ជាតិយើង ហើយសូមចូលរួមជាមួយគ្រប់ស្ថាប័នជាតិ បងប្អូនជនរួមជាតិទាំងអស់ វិស័យឯកជន អង្គការក្រៅរដ្ឋាភិបាល គណបក្សនយោបាយ ប្រែក្លាយជារៀងរាល់ឆ្នាំ ឱ្យទិវា ៩ ធ្នូ ជាការលើកកម្ពស់ និងបើកទូលាយមិនឈប់ឈរ ដើម្បីកសាងមាតុភូមិកម្ពុជា ឱ្យរៀចាកពីអំពើពុករលួយ និងស្គាល់តែភាពស្អាតស្អំ និងការរីកចម្រើនជានិច្ចកាល ។

ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ព្រះរាជាណាចក្រកម្ពុជា មិនមែនជារដ្ឋតែឯង ដើម្បីបំពេញនូវបេសកកម្មនេះឡើយ ។ អ៊ុនកាក់តែងតែបញ្ជូននូវអ្នកជំនាញមកកម្ពុជា ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍ អំពីក្របខ័ណ្ឌច្បាប់ ការចាត់តាំងអនុវត្តច្បាប់ និងការអនុវត្តនូវកាតព្វកិច្ច ដែល អ៊ុនកាក់ បានដាក់ចេញ ។ ជាមួយគ្នានេះដែរ អង្គភាពប្រឆាំងអំពើពុករលួយ នៃព្រះរាជាណាចក្រកម្ពុជា ក៏បានបញ្ជូនថ្នាក់ដឹកនាំរបស់ខ្លួនជាអ្នកជំនាញ ក្រោមឆ័ត្រអ៊ុនកាក់ ទៅត្រួតពិនិត្យការងារប្រឆាំងអំពើពុករលួយនៅប្រទេសនានា មាន

ទាំងប្រទេសនៅទ្វីបអឺរ៉ុប ទ្វីបអាស៊ី មជ្ឈិមបូព៌ា... ។

សម្រាប់ក្នុងប្រទេសវិញ ក៏មិនមែនមានតែស្ថាប័នប្រឆាំងអំពើពុករលួយតែឯង ដែលបំពេញនូវបេសកកម្មប្រយុទ្ធប្រឆាំងអំពើពុករលួយនោះដែរ ។ រាជរដ្ឋាភិបាល គ្រប់ស្ថាប័ន ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ វិស័យឯកជន សង្គមស៊ីវិល អ្នកសារព័ត៌មាន និងប្រជាជន បានរួមគ្នាមិនឈប់ឈរ អស់រយៈពេល ៦ អាណត្តិកន្លងទៅ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងការ ១)ការអប់រំ ដើម្បីម្នាក់ៗមិនចង់ពុករលួយ ២)ការបង្ការ ទប់ស្កាត់ ដើម្បីម្នាក់ៗមិនអាចពុករលួយ ៣)ការអនុវត្តច្បាប់ ដើម្បីឱ្យម្នាក់ៗមិនហ៊ានពុករលួយ ។ រាជរដ្ឋាភិបាល **សម្តេចតេជោ** អាណត្តិទី ៤ នាឆ្នាំ ២០១០ បានបង្កើតនូវស្នាដៃជាប្រវត្តិសាស្ត្រដែលនោះគឺជាការអនុម័តបាននូវច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងការបង្កើតនូវស្ថាប័នប្រឆាំងអំពើពុករលួយ ដែលមានអង្គចំនួន ២ គឺ ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងអង្គភាពប្រឆាំងអំពើពុករលួយ ។ រាជរដ្ឋាភិបាល **សម្តេចតេជោ** បានអនុវត្តជាបន្តបន្ទាប់នូវកំណែទម្រង់ស៊ីជម្រៅជាច្រើន ដែលបាននាំកម្ពុជា ក្លាយជាប្រទេសមួយមានកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយសង្គតិភាព ក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ។ បាវចនាដ៏ប្រជាប្រិយ ងាយចាំ ងាយយល់ ងាយអនុវត្ត ងាយនាំគ្នាកែទម្រង់ ៥ ពាក្យរបស់ **សម្តេចតេជោ «ឆ្លុះកញ្ចក់-ងូតទឹក-ដុសក្អែល-ព្យាបាល និងវះកាត់»** បានបញ្ជ្រាបចូលយ៉ាងឆាប់រហ័សដល់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ និងប្រជាជនគ្រប់ស្រទាប់ ។ មកដល់អាណត្តិថ្មី អាណត្តិទី ៧ នេះ រាជរដ្ឋាភិបាលដែលមានទូលព្រះបង្គំខ្ញុំ ខ្ញុំព្រះករុណាខ្ញុំជាប្រមុខ ក៏នៅតែបន្ត ហើយលើកកម្ពស់បន្ថែមទៀតនូវបាវចនា ៥ ពាក្យនេះ ហើយប្រាកដ ណាស់ បើយើង **ឆ្លុះកញ្ចក់ -ងូតទឹក-ដុសក្អែល-ព្យាបាល និងវះកាត់** បានជាប្រចាំ សង្គមយើង និងយើងម្នាក់ៗនឹងបន្តទទួលបានភាព ស្អាតស្អំ ក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ព្រមទាំងក្នុងការពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់ និងសន្តិភាពរបស់ព្រះរាជាណាចក្រកម្ពុជា។ **ឱ្យតែមានអ្វីមកប៉ះពាល់ប្រយោជន៍សាធារណៈ យើងរារាំងភ្លាម** ។

- **បងប្អូនជនរួមជាតិទាំងអស់ ជាទីស្រឡាញ់!**

តាំងពីយុទ្ធសាស្ត្រត្រីកោណ-ចតុកោណ និងនាពេលនេះ គឺយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ក្នុងនាមរាជរដ្ឋាភិបាលអាណត្តិថ្មី អាណត្តិទី ៧ នេះ ទូលព្រះបង្គំខ្ញុំ ខ្ញុំព្រះករុណាខ្ញុំ សូមបន្តវេភាពគំរូរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជំរុញការកែទម្រង់ ការពង្រឹងអភិបាលកិច្ច ដោយផ្តោតលើការ លើកកម្ពស់ និងការពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ ហើយរាជរដ្ឋាភិបាលសូមផ្តោតអាទិភាព លើការងារទាំង ៥ ដូចខាងក្រោម ៖

**ទី១-** ការរៀបចំ និងការដាក់ឱ្យអនុវត្តក្រមសីលធម៌វិជ្ជាជីវៈ និងក្រមប្រតិបត្តិក្នុងមុខងារសាធារណៈ ព្រមទាំងការជំរុញការគោរពខ្ជាប់ខ្ជួននូវគោលការណ៍វិសមិតភាពមុខងារ និងទំនាស់ផលប្រយោជន៍ នៅក្នុងការបំពេញការងាររបស់មន្ត្រីសាធារណៈ ។

**ទី២-** ការពង្រឹងប្រសិទ្ធភាព នៃការធ្វើអធិការកិច្ច និងសវនកម្ម ព្រមទាំងការរៀបចំក្របខ័ណ្ឌ និងវិធាន នៃប្រព័ន្ធអធិការកិច្ច និងសវនកម្ម ដើម្បីជានាសុខដុមនីយកម្ម នៃមុខងារអធិការកិច្ច និងសវនកម្ម ក្នុងរដ្ឋបាលសាធារណៈ ។

**ទី៣-** ការពង្រឹងយន្តការគ្រប់គ្រង និងផ្តល់សេវាសាធារណៈ ការផ្តល់ការលើកទឹកចិត្ត ផ្អែកលើគុណាធិបតេយ្យ និងការចាត់វិធានការម៉ឺងម៉ាត់តាមច្បាប់ ក្នុងការអនុវត្តតួនាទី និងភារកិច្ច ដើម្បីបង្កើនជំនឿទុកចិត្ត និងប្រសិទ្ធភាព នៃការផ្តល់សេវាសាធារណៈ ។

**ទី៤-** ការបន្តពង្រឹង និងពង្រីកលើការងារអប់រំ បង្ការ និងទប់ស្កាត់ជាចម្បង ព្រមទាំងការពង្រឹងការអនុវត្តច្បាប់យ៉ាងម៉ឺងម៉ាត់ ដើម្បីបង្ក្រាបបទល្មើសអំពើពុករលួយ ។

**ទី៥-** ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងអង្គភាពប្រឆាំងអំពើពុករលួយ និងស្ថាប័នសាធារណៈ ជាពិសេសតាមរយៈយន្តការជនបង្គោល ទាំងការងារអប់រំ និងការងារបង្ការទប់ស្កាត់ ដើម្បីរៀបចំដាក់ឱ្យអនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តផែនការយុទ្ធសាស្ត្រ និងលើកកម្ពស់ភាពស្អាតស្អំ នៅតាមស្ថាប័នសាធារណៈ ។

រាជរដ្ឋាភិបាលក៏សូមកោតសរសើរដល់រាល់ការប្រឹងប្រែងរែកពុនភារកិច្ចជាតិ - អន្តរជាតិ របស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងអង្គភាពប្រឆាំងអំពើពុករលួយ ដែលបានបំពេញកន្លងមក ដោយនាំមកនូវទំនុកចិត្ត ការគាំទ្រ និងការចូលរួមដ៏កុះករពីសំណាក់ ក្រសួង ស្ថាប័ន ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងមហាជនទូទៅ យ៉ាងរឹងមាំ ។

ក្រោមពាក្យស្លោក៖**«បម្រើផលប្រយោជន៍ប្រជាជនជាចម្បង ៖ ផ្តល់សេវាសាធារណៈប្រកបដោយតម្លាភាព ងាយស្រួល និងជឿទុកចិត្ត ពង្រឹងការបង្ការទប់ស្កាត់»** សម្រាប់ឆ្នាំ ២០២៤ ខាងមុខនេះ សូម គ្រប់ក្រសួងស្ថាប័ន អាជ្ញាធរគ្រប់ជាន់ថ្នាក់ វិស័យឯកជន ប្រជាជន មហាជនទាំងអស់ គាំទ្រ និងសហការជាមួយរាជរដ្ឋាភិបាល ជាមួយអង្គភាពប្រឆាំងអំពើពុករលួយ ដើម្បីបំពេញបេសកកម្មជាប្រវត្តិសាស្ត្ររបស់យើងបន្តទៀត រហូតដល់សម្រេចបំណងចុងក្រោយរបស់យើង គឺ**សង្គមស្អាតស្អំបវររុងរឿង** ។

ជាទីបញ្ចប់ ជាមួយនឹងឱកាស នៃការប្រារព្ធទិវាជាតិ - អន្តរជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ ៩ ធ្នូ ឆ្នាំ ២០២៣ ទូលព្រះបង្គំខ្ញុំ ខ្ញុំព្រះករុណាខ្ញុំសូមថ្វាយ និងប្រគេនពរ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមប្រសិទ្ធពរជ័យជូន សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា និងបងប្អូនជនរួមជាតិជាទីស្នេហា សូមសមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ៕

ថ្ងៃច័ន្ទ ៨រោច ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ ១២ ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**